# គុកជ្រៃអូរញ៉ោ

ដោយ ផេង ពង្សរ៉ាស៊ី

***ជ្រៃអូរញ៉ោ*** ជាឈ្មោះរបស់ភ្នំមួយដែលអ្នកស្រុក អ្នកភូមិនិយមហៅតាំងពីដើមរៀងមក ។ បច្ចុប្បន្ន ភ្នំនេះមានសង់ជាព្រះវិហារនៅចំពីលើកំពូលភ្នំ ហើយស្ទើរតែក្លាយជាទីកំសាន្តមួយនៃអ្នកទេសចរណ៍ទាំងឡាយ ។ ប៉ុន្តែប្រហែលជាមិនបានដឹងឡើយថា តើទីតាំងនេះមានរឿងរ៉ាវអ្វីខ្លះកើតឡើងកាលពីរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ មានតែអ្នកដែលមានប្រវត្តិជួរចត់នៅទីនោះ ឬប្រជាជនចាស់ៗប៉ុណ្ណោះដែលអាចដឹងប្រាកដថាមានរឿងយ៉ាងម៉េចខ្លះកើតឡើង ។ តាមពិតភ្នំនេះ គឺជាមន្ទីរសន្តិសុខមួយរបស់តំបន់៣៣ ដែលបង្កើតឡើងដោយគណៈភូមិភាគនិរតី ។ ជាច្រើនឆ្នាំកន្លងមក រឿងរ៉ាវកើតឡើងនៅមន្ទីរសន្តិសុខនេះនៅតែស្ថិតក្នុងផ្នត់គំនិតរបស់អ្នកដឹង ឮចាស់ៗមួយចំនួនដោយមិនបានរ៉ាយរ៉ាប់ឲ្យនរណាដឹងទាល់តែសោះ ។ ភាពពិតផតល្អៀងដែលធ្លាប់បានកើតមានឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទៅលើទីតាំងជុំវិញបរិវេណភ្នំនេះ នឹងត្រូវរលាយបាត់បន្តិចម្តងៗ ទៅតាមអាយុកាលនៃមនុស្សចំណាស់ៗទាំងនោះ ។ ក្មេងៗជំនាន់ក្រោយពិតជាមិនបានដឹងឡើយថា តើមានអ្វីកើតឡើងចំពោះទីតាំងភ្នំជ្រៃអូរញ៉ោនេះ! ។ ភាពអាថ៌កំបាំងនៃមន្ទីរសន្តិសុខជ្រៃអូរញ៉ោ ត្រូវបានទំលុះទំលាយបន្តិចម្តងៗ រហូតដល់មានការចុះទៅផ្ទាល់នៃបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទៅកាន់ទីតាំងនេះកាលពីថ្ងៃទី២៦ ខែមិនា ឆ្នាំ២០០១ ។ ក្នុងចម្ងាយដីជាង៨០គីឡូម៉ែត្រពីភ្នំពេញតាមផ្លូវជាតិលេខ៣និងក្នុងចម្ងាយដីជាងពីរគីឡូម៉ែត្រពីផ្សារដើមរការ(ប៉ែកខាងកើតថ្នល់ជាតិលេខ៣) តាមបណ្តោយផ្លូវគ្រួសក្រហមមួយខ្សែ ក្រុមយើងបានទៅដល់ភ្នំមួយដែលឈរជង្រ្គឹងប៉ែកខាងត្បូងផ្លូវលំមួយខ្សែនេះ ។ ភ្នំនោះគឺជាភ្នំជ្រៃអូរញ៉ោ ។ ភ្នំនេះគ្មានបានបន្សល់ទុកនូវអ្វីដែលជាភស្តុតាងធំដុំឡើយ ក្រៅពីស្រះទឹកដែលជីកដោយកម្លាំងអ្នកទោស និងអាគារបាក់បែកមួយខ្នងនៅពីមុខសាលាបឋមសិក្សារមួយ នៅជាប់ខាងកើតជើងភ្នំ ដែលកាលនោះជាមន្ទីរពេទ្យប្រចាំសហករណ៍ខាងកើតភ្នំ ។

មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងភូមិជើងភ្នំ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ តំបន់៣៣ ភូមិភាគនិរតី ហើយស្ថិតនៅក្នុងចំណុចខ្សែស្រប N: 11º 20 44.47 និងរយៈបណ្តោយ E: 104º 42 02.08 ។ មន្ទីរសន្តិសុខនេះត្រូវបានបង្កើតឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនាចុងឆ្នាំ១៩៧៦ ។ភ្នំជ្រៃអូរញ៉ោក្លាយជាចំណុចកណ្តាលនៃមន្ទីរសន្តិសុខនេះ ។ ហើយត្រូវបានផ្តល់ឈ្មោះឲ្យថា **មន្ទីរសន្តិសុខតំបន់៣៣** ឬ **មន្ទីរសន្តិសុខជ្រៃអូរញ៉ោ** ។ មន្ទីរសន្តិសុខនេះបានលេចចេញបន្ទាប់ពីមានការសម្លាប់មនុស្សដែលពួកខ្មែរក្រហមគិតថាជា

មនុស្សជាប់និន្នាការនយោបាយពីសង្គមមុន ។ មនុស្សដែលត្រូវជាប្តី ជាឪពុក ឬជាមេ គ្រួសារភាគច្រើនត្រូវបានសម្លាប់ បន្សល់តែកូនគ្មានឪពុក ប្រពន្ធព្រាត់ប្តី.......និងបន្តរស់ដោយភាពលំបាក លំបិនតាំងពីឆ្នាំ ១៩៧០មក ។

ពន្ធឺសុភមង្គលនៃក្រុមគ្រួសារដែលជាប់ចោទពីបទមានទាក់ទងទៅនឹងនិន្នាការនយោបាយពីសង្គម ត្រូវអន់ថយបន្តិចម្តងៗ រហូតស្ថិតក្រោមការគ្រប់គ្រងនៃបណ្តាសមមិត្តនៅមន្ទីរឃុំឃាំងជ្រៃអូរញ្ញៅ ។ នេះជាជោគវាសនាមួយដែលពួកគាត់ត្រូវតែទទួលដោយមិនអាចប្រកែកបានក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ។អ្នកធ្វើការនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញៅ គ្មានប្រជាជន ឬអតីតអ្នកទោសណាម្នាក់បានស្គាល់ច្បាស់ឡើយ ក្រៅពីតា ខុន(កំបុតដៃម្ខាង) ដែលជាប្រធានមន្ទីរសន្តិសុខ និងតា បែន ជាអនុប្រធាន ។ លើសពីនេះអ្នកស្រុកភាគច្រើនដែលរស់នៅក្នុងឃុំវាលបានពន្យល់យ៉ាងក្បោះក្បាយថា សុទ្ធតែជាសមាសភាពមកពីក្រៅទាំងអស់ ។ អ៊ំប្រុសខៀវ ឡូបាននិយាយថា“ពួកវាសុទ្ធតែនិយាយអន្ទឹនៗ” ។ គ្មានពួកសន្តិសុខណាម្នាក់មានដើមកំណើតរស់នៅភូមិក្បែរៗមន្ទីរសន្តិសុខនេះឡើយ ។ មាស មាំង ប្រាប់ថា “ពួកអាសន្តិសុខនេះ ភាគច្រើនៗមកពីខាងជាំសង្កែ(ស្រុកថ្ពង) ឬកាត់ភ្លុក មិនមាននៅនេះទេ” ។

ឯកសារខ្មែរក្រហមប្រមូលពីភូមិភាគនិរតីរាប់ពាន់សន្លឹករួមនឹងឯកសារស្រាវជ្រាវរបស់ក្រុមផែនទី និងរណ្តៅសាកសពនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជាក់ថា ភូមិភាគនិរតីស្ថិតក្រោមការគ្រប់គ្រងរបស់តាម៉ុកក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ហើយក៏ជាភូមិភាគឈានមុខ និងគំរូមួយក្នុងវិស័យបោសសម្អាតខ្មាំងគ្រប់ប្រភេទរបស់អង្គការ ។

ពាក្យ“**បដិវត្តន៍កម្មុច ឬ អង្គការកម្មុច**” ជាពាក្យដែលអ្នកទោសដែលជាប់នៅមន្ទីរសន្តិសុខជ្រៃអូរញ្ញៅធ្លាប់ឮឡើងសាំុត្រចៀកទៅហើយ ហើយក៏ជាពាក្យមួយម៉ាត់ដែលធ្វើឲ្យពួកគាត់ដែលសេសសល់ពីស្លាប់មានការឈឺចាប់អស់មួយជីវិត ។ លោកយាយ អ៊ំ ណាប់ តួញត្អែរថា “មូលហេតុពួកខ្មែរក្រហមចាប់ខ្លួនខ្ញុំយកទៅដាក់នៅជ្រៃអូរញ្ញៅព្រោះគ្រួសាររបស់ខ្ញុំត្រូវបដិវត្តន៍កម្មុច” ។ ប្តីរបស់លោកយាយត្រូវពួកខ្មែរក្រហមបញ្ឆោតដោយសរសេរសំបុត្រមកប្រាប់ថា ឲ្យទៅមើលថែរក្សាបងរបស់គាត់ម្នាក់ទៀតដែលជាគ្រូសង្ឃរាជដែលកាលនោះពាក្យសំដីនៅក្នុងសំបុត្របានបញ្ជាក់ថា “គាត់មានទុក្ខធ្ងន់ណាស់” ។ តាមពិតគ្រូសង្ឃរាជនោះត្រូវបានពួកខ្មែរក្រហមយកទៅសម្លាប់ចោលរួចទៅហើយកាលពីឆ្នាំ១៩៧០ ។ អស់ពេលជាយូរទើបដឹងថាប្តីត្រូវស្លាប់ដោយពាក្យបោកប្រាស់របស់ពួកអាទមិឡខ្មែរក្រហម ។ លោកយាយបន្តថា “ពេលបាត់គាត់ ខ្ញុំខំដើររកគ្រប់ច្រកល្ហក ។ ទៅសួររហូតដល់ប្រធានភូមិទៀត ទីបំផុតទើបប្រធានភូមិនោះប្រាប់ខ្ញុំថា ប្តីខ្ញុំត្រូវបដិវត្តន៍កម្មុចបាត់ហើយ” ។ លោកយាយបានត្រឹមបង្ហូរទឹកភ្នែកស្ទើរតែរាល់ថ្ងៃ ដោយមិនហានស្តីបន្ទោស ឬទាម

ទារឲ្យអង្គការសងប្តីសំឡាញ់របស់គាត់វិញឡើយ ព្រោះខ្លាចពួកអាឈ្លបទាំងនោះយកគាត់ទៅសម្លាប់ទៀត ។ លោកយាយអធិប្បាយទាំងទឹកភ្នែកថា “ប្រធានភូមិនោះមិនឲ្យខ្ញុំនិយាយខ្វះខ្វាយទៅក្រៅទេ ព្រោះខ្លាចគេយកប្រពន្ធទៅទៀត” ។ មិនត្រឹមតែគ្រួសារលោកយាយប៉ុណ្ណោះទេដែលទទួលការបែកបាក់គ្រួសារ នៅមានគ្រួសារជាច្រើនទៀតដែលមិនអាចគេចផុតបានដូចគ្នា ។ ដោយសារតែភាពម៉ឺងម៉ាត់ មួរម៉ៅ បូករួមទាំងភាពគ្មានមេត្តាធម៌ ដែលស្របនឹងពាក្យបូរាណមួយឃ្លានិយាយថា “ដកស្មៅត្រូវដកទាំងឫស” របស់ពួកខ្មែរក្រហមស្រាប់តែលេចចេញនូវមន្ទីរឃុំឃាំងមួយដែលមិនអាចស្មានដល់ថា ជាមន្ទីរសម្រាប់ឃុំឃាំងនូវពពួកមនុស្សដែលមានជាប់ខ្សែស្រឡាយជាមួយពួកអ្នកដែល“អង្គការកម្ទេច” ។ ប្រាក់ សារិន ជាជំទប់លេខ២ឃុំវាលស្រុកគងពិសី បាននិយាយពន្យល់ថា “អ្នកទោសដែលមកជាប់នៅគុកជ្រៃអូរញ៉ោនេះ សុទ្ធសឹងតែជាអ្នកដែលមានគ្រួសារបដិវត្តន៍កម្ទេច នេះមានន័យថាឲ្យតែមានកូន ប្តី ប្រពន្ធនៅក្នុងបន្ទុក ហើយត្រូវអង្គការយកទៅសម្លាប់នោះ គឺគ្រួសារហ្នឹងត្រូវយកទៅដាក់នៅក្នុងហ្នឹងទាំងអស់” ។ ក្នុងការប្រមូលយកទៅនេះគឺសូម្បីតែក្មេងតូចៗ ឬចាស់ជរានៅក្នុងបន្ទុកដែលដើរមិនរួច ក៏ពួកខ្មែរក្រហមយកទៅទាំងអស់ដែរ ។ ប្រាក់ សារិន បន្តថា “ព្រោះបានយើងថាអញ្ចឹង គឺប្រហែលមកពីគេថាអាចប្រមូលផ្តុំ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង និងរិតបន្តឹង ។ ព្រោះយើងសុទ្ធតែដឹងថាគ្រួសារនោះ សុទ្ធតែគ្រួសារអ្នកដែលមានកំហឹងជាមួយអង្គការរបស់គេ” ។ ប្រជាជនម្នាក់រស់នៅភូមិព្រៃខ្ទុង ឃុំវាលបាននិយាយពីការចាប់យកមនុស្សទៅដាក់នៅជ្រៃអូរញ៉ោថា ចាប់មិនដែលមានខុសម្តងណាឡើយ ព្រោះពួកកងឈ្លប ឬប្រធានភូមិ ឃុំរបស់គេសុទ្ធតែមានបញ្ជីចាប់ខ្លួនត្រឹមត្រូវ ។ ប្រាក់ គី ជាប្រជាជនរស់នៅក្នុងភូមិខ្ទុងដែរ បានរៀបរាប់ថា ពេលដែលមេចាប់ខ្លួននោះ គឺមិនមែនមកចាប់យកទៅតែម្តងទេ គឺពួកកងឈ្លបខ្មែរក្រហមមេនិយាយយ៉ាងសម្រួលឥរិយាបទ មានភាពគួរសមព្រមទាំងកាយវិការទន់ភ្លន់ ។ តាមពិតកាយវិការ និងពាក្យសម្តីរបស់ពួកគេសុទ្ធតែផ្ទុយទៅនឹងធាតុពិតដែលពួកគេធ្លាប់មាន ។ ប្រាក់ គី និយាយទាំងបញ្ឈរជង្គង់ក្រោមផ្ទះរបស់គាត់ថា “ឥឡូវអ្នកឯងអង្គការឲ្យទៅជួបជុំជាមួយប្តីនៅជ្រៃអូរញ៉ោ” ។ អ៊ឹំស្រីមិនជឿ គាត់ក៏និយាយបន្តថា“ អត់ទេ! បងនិយាយកុហក់ខ្ញុំទៀតហើយ ខ្ញុំដឹងថាប្តីរបស់ខ្ញុំស្លាប់ហើយ ខ្ញុំមានទោសអី កុំយកខ្ញុំទៅអី” ។ ប្តីរបស់អ៊ឹំស្រី ត្រូវពួកប្រធានសហករណ៍បញ្ឆោតយកទៅសម្លាប់រួចទៅហើយកាលពីខែមករា ឆ្នាំ១៩៧៦ ដោយយកឡេសថា ឲ្យទៅដឹកជញ្ជូនឲ្យវ៉ាន់ពីសហករណ៍ ។ ទីបំផុតប្តីរបស់គាត់ត្រូវស្លាប់ដោយគ្មានដំណឹង ។ ដោយមិនអាចប្រកែកបានមន្ទីរសន្តិសុខជ្រៃអូរញ៉ោបានទទួលស្វាគមន៍អ៊ឹំស្រី ប្រាក់ គីឲ្យស្នាក់នៅជាមួយក្រុមគ្រួសារដទៃជាច្រើនទៀតពេញថេរវេលានៃការកាន់អំណាចរបស់កម្ពុជាប្រជាធិបតេយ្យ១៩៧៥-៧៩ ។

មិនត្រឹមតែទទួលឲ្យចូលតែគ្រួសារអ្នករងគ្រោះដោយ "បដិវត្តន៍កម្មេច" ប៉ុណ្ណោះទេ មន្ទីរសន្តិសុខនេះមានទទួលយកមនុស្សពីតំបន់២៥ បូករួមទាំងទាហានពីភូមិភាគបូព៌ាផងដែលកាលនោះត្រូវបានចោទថា ក្បត់ហ្នឹងអង្គការបក្ស ។ ប្រាក់ សារិន ប្រាប់ថានៅឆ្នាំ១៩៨២ កាលនោះគាត់ជានគរបាលឃុំ ។ គាត់រួមជាមួយមន្ត្រីថ្នាក់ឃុំ ស្រុកជាច្រើនរូបទៀតបានទៅគាស់រណ្តៅសាកសពជាច្រើនកន្លែងជុំវិញបរិវេណមន្ទីរសន្តិសុខជ្រៃអូរញៀ ។ ពេលនោះគាត់បានឃើញទាំងស្រស់ៗនូវខោអាវទាហានពណ៌ត្រួយចេកដែលស្រោបខ្លួនសាកសព ដែលមានចំនួនរាប់រយនាក់ ។ គាត់ស្គាល់ច្បាស់ថា នេះជាខោអាវទាហានភូមិភាគបូព៌ា ។ លោកយាយណាប់ បញ្ជាក់ថាបានឃើញពួកខ្មែរក្រហមដឹកមនុស្សមកទាំងឡានៗចូលមៅកាន់ជ្រៃអូរញៀ ប៉ុន្តែក្រោយមៅមិនដែលឃើញពួកទាំងនោះឡើយ ។ ទាហានជាច្រើន ត្រូវបានលោកយាយរាយការណ៍ថា ដឹកម្តងពី៥ទៅ៦ឡានចូលមៅ ហើយឃើញតែសំបកឡានទទេរចេញទៅវិញ ។ រំលងមួយថ្ងៃ ឬពីរថ្ងៃគឺមានដឹកមៅម្តង ។ ប្រជាជនថ្មីដែលដឹកយកមៅទាំងឡានៗដែរនោះ ក៏មិនដែលរស់នៅបានយូរដែរ ។ នេះជាសំដីរបស់យាយណាប់ ។ ពេលណាបាត់ប្រជាជនទាំងនោះ មួយសន្ទុះក្រោយមៅគឺពិតជាមានយកខោអាវយកមៅចែកឲ្យអ្នកទោសហើយ ។ សាក្សីម្នាក់បានប្រាប់ថា ខោអាវទាំងនោះគឺជាខោអាវអ្នកដែលស្លាប់ទៅថ្មីៗ ។

មនុស្សម្នាក់ៗនៅជ្រៃអូរញៀ សុទ្ធតែបានទទួលការងារយ៉ាងច្រើនមកធ្វើតែក្នុងរយៈពេលមួយថ្ងៃ ។ មាស លាភនិយាយទាំងហួសចិត្តថា "បន្ទាប់ពីគេយកខ្ញុំមៅភ្ជុំជ្រៃអូរញៀមកគេប្រើខ្ញុំខ្លាំងជាងនៅអីក្រៅទៀត ។ ខ្ញុំគេឲ្យភ្ជួរស្រែពីម៉ោង៣ភ្លឺដល់ម៉ោង១២ថ្ងៃត្រង់បានឲ្យឈប់ ។ ភ្ជួរហើយហ្នឹងគេអត់ឲ្យឈប់ទេគេឲ្យឃ្វាលគោម្នាក់៣នឹមទៀត ។ ឃ្វាលគោ៣នឹមហើយ ម៉ោង៣ចាប់ភ្ជួរទៀត ។ អាសល់ពីនោះ អ្នកអត់ឃ្វាលគោនឹងគេឲ្យទៅឆ្ការព្រៃ" ។ ការងារនៅក្នុងមន្ទីរសន្តិសុខជ្រៃអូញៀ ត្រូវបានបែងចែកជា កម្លាំងទី១ ទី២ ទី៣....ទៀត ។ អ្នកទោសណាដែលមានកម្លាំងខ្លាំង ត្រូវចូលទៅក្នុងកម្លាំងទី១ អ្នកបន្ទាប់គឺទី២ ហើយអ្នកខ្សោយបំផុត ដូចយាយៗ ត្រូវស្ថិតនៅក្នុងកងមើលចៅ ឬមើលក្មេងតូចៗដែលម្តាយត្រូវទៅធ្វើការឆ្ងាយៗពីកន្លែង ។ ជួលកាលក៏ខ្មែរក្រហមប្រើឲ្យទៅធ្វើស្រែ វែកដីដែរ ។ អ៊ំស្រីប្រាក់ គី ស្ថិតក្នុងកងដកស្ទូង វែកដី លើកទំនប់ ជីកប្រឡាយ ឬជីកស្រះ...។ កូនខ្ចីរបស់គាត់ត្រូវយកទៅឲ្យយាយៗ ជាអ្នកមើលថែ ។ ពេលល្ងាច ឬយប់ម៉ោង ៨ ម៉ោង៩ បានគាត់ទៅយកកូនពីយាយៗ មកឲ្យបៅដេក ។ ការងារមិនកំណត់ថាយប់ ឬថ្ងៃឡើយ ។ កាលណាខែភ្លឺ កងនារី យុវជនត្រូវទៅធ្វើការទាំងយប់តាមផែនការដាក់ចុះពីគណៈកង ។ បងស្រី មាស រុំ អាយុ ៣៨ ឆ្នាំ រស់នៅភូមិព្រៃខ្វង ឃុំវាល និយាយទាំងអស់សំណើចថា "ជួនកាលពួកខ្ញុំវែកដី ប្រណាំងគ្នាដើម្បីហូបឆ្អែត" ។ គ្មានមធ្យោបាយណាមួយអាចឲ្យបងស្រី និងអ្នកឯទៀតហូបបានឆ្អែតឡើយ ។ លើកលែងតែថ្ងៃទី១០ និងទី២០ ជារៀងរាល់ខែដែលអាចហូបឆ្អែតបាន ។ ជិទប់ទី២ឃុំវាលបានពន្យល់ថាឲ្យតែដល់ថ្ងៃ

ទី១០ និងទី២០ គឺពួកខ្មែរក្រហមវាបន្ទរបន្ទុយច្រើនដល់ការជួបជុំសាច់ញ្ញាតិ   បងប្អូន   ប្តី   ប្រពន្ធដែលនៅក្នុងបរិវេណគុកប៉ុណ្ណោះ ។  ការហូបចុកគឺបានឆ្អែតល្មម  ដែរ ។

មានសហករណ៍ចំនួន៦ ជាចំណុះរបស់មន្ទីរសន្តិសុខព្រៃអូរញ៉ៅ ។  សហករណ៍ទាំងនេះសង់ជារោងវែងៗ ដែលផ្ទុកមនុស្សជាច្រើនពាន់នាក់ ។  ប៉ុន្តែសុទ្ធតែមានការបែងចែកតាមប្រភេទកម្លាំង ។  តាមសហករណ៍មួយៗ គឺមានមន្ទីរពេទ្យមួយសម្រាប់ព្យាបាល ។    លោកយាយណាប់បានប្រាប់ថា    ពេទ្យនេះអាចព្យាបាលបានតែប្រភេទជម្ងឺធ្ងន់ៗប៉ុណ្ណោះ ។   ទោះជាយ៉ាងនេះក៏ដោយ   មនុស្សស្លាប់មានជារៀងរាល់ថ្ងៃដោយសារតែឈឺនិងអត់បាយ ។  អ្នកជិតខាងយាយណាប់  បានស្លាប់ដោយសារជម្ងឺ ។  អ្នករួមការងារជាមួយបងស្រីមាស  រុំបានស្លាប់ដោយសារឃ្លានខ្លាំងពេក ។  បងស្រី  រុំបាននិយាយថា  “ខ្ញុំបានជួបប្រទះមនុស្សស្លាប់ក្បែរខ្លួនពីរ  បីដង ដូចជាឈ្មោះ  ថុល  ម្នាក់ទៀតឈ្មោះ  ម៉ាប់  និងម្នាក់ទៀតភ្លេចឈ្មោះ” ។

ទិដ្ឋភាពសម្លាប់មនុស្សទាំងកណ្តាលថ្ងៃ    ខ្មោចស្លាប់ក្បែរខ្លួនទាំងកណ្តាលអាធ្រាតមិនត្រឹមធ្វើឲ្យមនុស្សមានវ័យ៤០ឆ្នាំដូចមីងគី  លែងខ្លាចខ្មោច  សូម្បីតែក្មេងស្រីអាយុទើប១៣ឆ្នាំដូចរុំ  លាភ  និងសារឿនក៏នឹកមិនឃើញរឿងខ្លាចខ្មោចអាបដែរ ។  រុំ  រំឭកថា  “ដំបូងខ្ញុំភ័យយំរាល់យប់  ដល់យូរៗទៅធម្មតា  បើយប់ណាក៏មានងាប់  យូរទៅដូចជារស់នៅជាមួយខ្មោចទៅហើយ ។  ក្នុងក្រុមកុមារី  យប់ណាក៏មានងាប់ដែរព្រោះពេលយើងវិលត្រឡប់មកពីធ្វើការវិញហេវហត់    ឈឺរងា    ខ្លួនទទឹកជោគ         ហើយនាំគ្នាចូលដេកអត់មានមុងភួយអ្វីទាំងអស់ ។  ព្រលឹមឡើងពេលមេកង  មកដាស់ឲ្យងើបឡើងទៅធ្វើការខ្លះរឹងស្តូកងាប់បាត់ទៅហើយ” ។

បញ្ហានយោបាយមិនត្រូវបានបញ្ចុះបញ្ចូលដល់អ្នកទោសចាស់ៗឡើយ      មានតែការប្រជុំការងារម្តងម្កាលប៉ុណ្ណោះពីប្រធាន  និងអនុប្រធានគុក  គឺតាខុន  និងតាបែន ។  ប៉ុន្តែមានកើតឡើងខ្លះនូវការបញ្ចុះបញ្ចូលផ្នែកមនោគមវិជ្ជាចំពោះកុមារ ។  អង្គប្រជុំក្នុងក្រុមកុមារវិញ  តាមអតីតអ្នកទោសក្នុងសហករណ៍កុមារឲ្យដឹងថា ការប្រជុំម្តងៗគឺនិយាយតែអំពីការបំពាក់បំប៉នកុមារឲ្យខំធ្វើការងារឲ្យស្រឡាញ់អង្គការបដិវត្ត    ឲ្យមានចិត្តដាច់ខាត ។  ដូចសារឿន  រំឭកអំពីការបំពាក់បំប៉នមនោគមន៍វិជ្ជារបស់ប្រធានក្រុមកុមារ  ក្នុងអង្គប្រជុំក្រុមកុមារនៅខាងជើងភ្នំព្រៃអូញ៉ៅថា“  រ៉ា  ប្រធានក្រុមខ្ញុំថ្ងៃមួយគាត់ប្រជុំណែនាំកុមារ  យើងឲ្យខំធ្វើការបម្រើអង្គការ ព្រោះយើងជាកូនរបស់អង្គការ ។  កុមារត្រូវតែដាច់ខាត  មិនត្រូវស្តាយស្រណោះអាឡោះ  អាល័យអ្វីទាំងអស់ ។  ឪពុកម្តាយយើងធ្វើខុសដូច្នេះត្រូវតែស្លាប់  ហើយយើងក៏ត្រូវតែហ៊ានសម្លាប់ឪពុកម្តាយយើងដែរ” ។ ពេលនិយាយចប់  រ៉ា  សួរកុមារក្នុងអង្គប្រជុំថា“មើលមិត្តយើងណាខ្លះហ៊ានសម្លាប់ឪពុកម្តាយ?  បើហ៊ានត្រូវលើកដៃ” ។  ពេលនោះទាំងខ្ញុំទាំងគេលើកដៃទាំងអស់គ្នា” ។

ក្រៅពីនេះទៅមានការប្រជុំជារៀងរាល់ថ្ងៃពីសំណាក់ប្រធានកងហា ប្រធានកងវរយ ឬ ប្រធានក្រុម ជាមួយកូនក្រុមរបស់ខ្លួនដែលជាអ្នកទោសដូចគ្នា ។ គួរ រំលឹកដែរថាប្រធានកងហា វរយ ឬប្រធានក្រុម សុទ្ធសឹងតែជាអ្នកទោសដែលកសាងខ្លួនបានល្អតាមមាគ៌ា របស់អង្គការកាលនោះ ។ ពួកទាំងនោះត្រូវបាន តំឡើងឋានៈឲ្យដោយប្រធានគុក ពេលដែលអ្នកទោសនោះ ក្លាយជាមនុស្សគួរឲ្យទុកចិត្ត ។ យាយណាប់ រំឭក ថា "ពួកគេសុទ្ធតែកសាងខ្លួនបានហើយ បានឡើងជាប្រធាននោះ" ។ ការប្រជុំរបស់ប្រធានក្រុម ប្រធាន កងហា កងវរយគឺកើតមានជារៀងរាល់ល្ងាចពេលបាយហើយ ។ មាស លាភ បានឲ្យដឹងថា" ប្រជុំរាល់ថ្ងៃ ។ គេប្រជុំថាឲ្យយើងខំធ្វើការ ។ មេគេធំៗ គឺប្រធានក្រុមហ្នឹងអ្នក បើកអង្គប្រជុំ ។ មុនដំបូងថ្ងៃនឹងប្រជុំប្រធាន ក្រុម ស្អែកប្រធានកងហា ប្រធានកងវរយវិលមៅក្រុមតូចៗវិញ ទៀតអត់ទំនេរទេវិលរហូត" ។ បើអ៊ឹ ស្រី ប្រាក់ គី និងយាយ អ៊ំ ណាប់បានបញ្ជាក់ថា ពេលប្រជុំម្ដងៗ ឮ តែពាក្យ "ស្លាប់" ជាប់តែហ្នឹងមាត់ ។ ឧទាហរណ៍ដូចមេកងគេថា "ឲ្យនាំគ្នាខំធ្វើការ ប្រយត្ន័ស្លាប់" "កុំឲ្យលួចគេ ប្រយត្ន័ស្លាប់"... ។ ដូចសម្ដី តាបែននិយាយកាលបើកអង្គប្រជុំ ហើយត្រូវយាយណាប់ចាប់អារម្មណ៍លើកមកនិយាយថា "បែន និយាយ ពេលប្រជុំឲ្យប្រយត្ន័ខ្លួន ឥឡូវដល់ពេលចម្រាញ់ ដូចអង្ករអញ្ចឹងគឺយើង ចម្រាញ់យកតែដើម យកតែអាល្អ អាចុងមិនយកទេ ក្រវាត់ចោលហើយ" ។

វិន័យនៅក្នុងមន្ទីរសន្តិសុខជ្រៃអូរញ្ញៅពិតជាពិបាកប្រណិបត្តតាមណាស់ ។ មូលហេតុអត់ឃ្លាន ធ្វើឲ្យ មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់នៅជ្រៃអូរញ្ញៅស្លាប់ជាបន្តបន្ទាប់ ហើយក៏រឹតតែធ្វើឲ្យមនុស្សចេះលួច ហ៊ាន ល្មើសនឹងច្បាប់ដែលបានដាក់ចុះ ។នេះក៏ជាបញ្ហាមួយធ្វើឲ្យមនុស្សដែលជាអ្នកទោសគុកជ្រៃអូរញ្ញៅស្លាប់អស់ជា ច្រើនដែរ ។ អ្នកទោសម្នាក់ត្រូវបានស្លាប់ដោយសារតែរើសកូនកង្កែបមួយនៅពេលដែលខ្លួនកំពុងតែភ្ជួររាស់ ។ យាយណាប់រំឭកថា "កាលនោះខ្ញុំអាណិតតានោះណាស់ ខ្ញុំឃើញពួកកងឈ្លបចាប់វ៉ៃគាត់នឹងគល់ឫស្សី ហើយ បណ្ដើរគាត់យកទៅបាត់ទៅ ។ ខ្ញុំភ័យខ្លាំងណាស់ ខ្ញុំមិនហ៊ានលួចបេះបោចអ៊ីបន្តិចទេ ខ្លាចស្លាប់ណាស់" ។ លោកពូប្រាក់ សារិន បានអធិប្បាយយ៉ាងក្បោះក្បាយថា "បន្ទុកនៃការទទួលខុសត្រូវក្នុងការសម្លាប់មនុស្ស នៅភូមិភាគនិរតីគឺយើងពិបាកនិយាយណាស់ បើយើងនិយាយឲ្យចំទៅថា សម័យនោះបើចង់សម្លាប់ ឬមិនចង់ សម្លាប់មិនចាំបាច់សុំយោបល់ពីថ្នាក់លើទេ គឺថាវាមានទៅហើយ យើងនិយាយអញ្ចេះទៅចុះ គឺគេមានសិទ្ធិ ទៅហើយ កម្មាភិបាលមួយៗ សម្លាប់មនុស្សដូចសម្លាប់កូនកង្កែបមួយ វ៉ៃផោះចោលក៏មាន ។ តែសិទ្ធិអាហ្នឹង មូលហេតុថាអ្នកឯងចង់សម្លាប់ ឬមិនចង់សម្លាប់ ថ្នាក់លើមិនគាបសង្កត់ មិនយកទោសទេ" ។ ប្រហែលមកពី ដូចសំដីខាងលើនេះហើយ បានជាអ្នកទោសខ្លះដែលនៅរស់ស៊ូទ្រាំគោរពបញ្ជាទាំងទឹកភ្នែក ដើម្បីថែរក្សាអាយុ ជីវិតឲ្យបានវែង ។ ចំណែកអ្នកដែលបានស្លាប់ទៅគឺត្រូវអូសយ៉ាងទីណាត់ទីណែងយកទៅកប់ចោល ។ តាមការ

របស់បងស្រី មាស រ៉ុថា ចំនួនអ្នកទោសដែលស្លាប់ដោយជម្ងឺ និង អត់បាយ មានចំនួនស្មើរតែស្មើគ្នានឹងអ្នកដែលត្រូវយកទៅសម្លាប់ ។ ប្រាក់ សារីន ប្រាប់ថា ពេលគាត់ចូលរួមគាស់រណ្ដៅសាកសព គាត់សង្កេតឃើញថា មានលលាដ៏ក្បាលខ្លះមានផុង ប្រេះស្រាំ ឬបែកតែម្ដង ។ នេះគាត់បានសន្និដ្ឋានថា ពិតជាអ្នកទោសដែលត្រូវយកមកវៃសម្លាប់ហើយ ។ សាកសពរបៀបនេះមានច្រើនណាស់ រហូតដល់រាប់រយឯណោះ ។ ចំណែកសាកសពខ្លះទៀត គឺមានទ្រង់ទ្រាយនៅល្អទាំងអស់ ។ កន្លែងដែលកប់សាកសព គឺស្ថិតនៅចម្ងាយប្រហែលជាងពីរគីឡូម៉ែត្រពីមន្ទីរសន្តិសុខ ដូចជានៅ ព្រៃស្ដេច ព្រៃខ្ទុង វត្តចំប៉ា”.... ។

ក្រោយបែកឆ្នាំ១៩៧៩ មានភាគតិចណាស់ដែលបានរួចរស់ជីវិតចេញពីពិភពខ្មៅងងិតព្រៃអូរញ្ញោ ។ អ្នកដែលនៅរស់ទាំងនោះ ម្នាក់ៗសុទ្ធតែមានបាត់សមាជិកគ្រួសាររបស់ខ្លួនអស់ស្ទើរតែទាំងអស់ ។ មាស លាភ និងប្អូនស្រីបង្កើត មាស រ៉ុ បានរ៉ាយរ៉ាប់ទាំងអួលដើមកថា ពួកគាត់បានបាត់បង់ម្ដាយជាទីស្រឡាញ់នៅពេលដែលអង្គការចាប់ម្ដាយនិងកូនពីរនាក់ទៅដាក់នៅគុកព្រៃអូរញ្ញោ បន្ទាប់ ពីពីរខែនៃការចាប់ខ្លួនឪពុករបស់គាត់យកទៅកម្ទេច ។ មីងសុន បានឲ្យដឹងថា“ជីវិតកូនស្រីពៅអាយុ៥ឆ្នាំរបស់គាត់ម្នាក់បានស្លាប់យ៉ាងវេទនាបំផុតនៅព្រៃអូរញ្ញោ” ។ គួររំឭកដែរថានៅឆ្នាំ១៩៧៧ មីងសុន រួមនឹងមនុស្ស១៧នាក់ផ្សេងទៀតក្នុងភូមិភ្នំតូច ឃុំសូភី ស្រុកបាទី ខេត្តតាកែវត្រូវបានចាប់ខ្លួន ហើយបញ្ជូនតាមរទេះគោ២ទៅកាន់មន្ទីរសន្តិសុខភ្នំព្រៃអូរញ្ញោ ។ មីងសុន រំឭកអំពីមូលហេតុនៃការចាប់ខ្លួនពួកគាត់តាមការប្រាប់របស់ប្រធានភូមិថា “ដោយសារយើងទាំងអស់គ្នាបានរៀបការក្លាយជាប្រពន្ធ និងកូនខ្មាំងរបស់អង្គការ” ។ មីងគី បានស្លាប់កូនអស់ប្រាំនាក់នៅព្រៃអូរញ្ញោតែក្នុងរយៈពេលពីរឆ្នាំប៉ុណ្ណោះ បូករួមទាំងប្ដីមួយទៀតដែលត្រូវអង្គការកម្ទេចកាលពីខែមករា ឆ្នាំ១៩៧៦គឺចំពេលដែលគាត់កំពង់មានផ្ទៃពោះ៣ខែ ។

អតីតឃាតករដៃដេតខ្មែរកាត់ចិន កាំង ហ្កេច អៀវ ហៅឌុច គណៈមន្ទីរ ស-២១ឬគុកទួលស្លែងក្នុងបទសម្ភាសន៍ជាមួយលោក ណេត ថៃយ័រ បានបកអាក្រាតអំពើ សម្លាប់ប្រជាជនភូមិភាគនិរតីរបស់តាម៉ុកនៅភ្នំព្រៃអូរញ្ញោថា “ក្រោមការគ្រប់គ្រងរបស់តាម៉ុក អ្នកទោសក្នុងមន្ទីរសន្តិសុខភូមិភាគនិរតីនៅភ្នំព្រៃអូរញ្ញោជាច្រើនត្រូវបានសម្លាប់ដោយគ្មានការសួរនាំអ្វីទាំងអស់” ។ កស្សិណនេះត្រូវបានបញ្ជាក់កាន់តែច្បាស់ថែមទៀតនូវចំនួនសាកសពដែលគាស់បានក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដោយក្រុមស្រាវជ្រាវនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ សារិន ដែលបានចូលរួមគាស់រណ្ដៅសាកសពក្នុងឆ្នាំ១៩៨២ បានបញ្ជាក់ថា “ទីតាំងសម្លាប់អ្នកទោសរាប់ម៉ឺននាក់មាននៅពីរកន្លែងធំៗគឺក្នុងភូមិព្រះស្ដេច និងភូមិព្រៃខ្ទុង ។

ស្ត្រី និងកុមាររាប់ម៉ឺននាក់ត្រូវបាត់ស្លាប់បង់ជីវិតនៅមន្ទីរសន្តិសុខភ្នំព្រៃអូរញ្ញោ ដែលបង្កើតឡើងដោយភូមិភាគ ។ ស្ត្រី និងកុមារដែលសល់ពីស្លាប់ក្លាយជាស្ត្រីមេម៉ាយ និងក្មេងកំព្រា ។ យាយណាប់ សព្វថ្ងៃ

រស់នៅតែម្នាក់ឯង គាត់ធ្វើការងារគ្រប់បែបយ៉ាងតាំងពីភ្ជួររាស់ ដកស្ទូង និងការងារក្នុងផ្ទះ ។ ក្រៅពីវាលស្រែ និងក្នុងផ្ទះយាយណាប់ គ្មានអារម្មណ៍ចង់ដើរទៅណាមកណាឡើយ ។ យាយណាប់ ប្រាប់ហេតុផលថា "ខ្ញុំនឹកតូចចិត្ត ខ្លួនមានតែមួយ គ្មានឪពុកម្តាយប្តីសី កូនចៅនៅជាមួយដូចគេ" ។ យាយណាប់ បានបញ្ឈរក់ពីចិត្តស្មោះរបស់គាត់ទាំងទឹកភ្នែករហាម និងសំឡេងអួលដើមកថា "ពេលណាធ្វើដំណើរ កាត់ភ្នំជ្រែអូញ៉េម្តងៗ ខ្ញុំតែងស្រមៃឃើញមនុស្សម្នាក្នុងសម្លៀកបំពាក់ខ្មៅ រូបរាងស្គមស្គាំង ប្រឹងដើរសំដៅទៅធ្វើការងារ ។ អ្នកខ្លះត្រូវចាប់វៃធ្វើបាប និងសម្លាប់ ។ ព្រៃកភូមិជើងភ្នំជាកន្លែង ដែលខ្មែរក្រហមកំណត់ព្រំប្រទល់មន្ទីរសន្តិសុខជ្រែអូញ៉េ ។ព្រៃកនេះធ្វើឲ្យខ្ញុំចាំមិនភ្លេចអំពីម្តាយរបស់ខ្ញុំ ។ពេលដែលខ្ញុំត្រូវចាប់ខ្លួនហើយបញ្ជូនមកភ្នំជ្រែអូញ៉េ ម្តាយខ្ញុំរត់តាមជូនដំណើរខ្ញុំ មកដល់ព្រៃកនេះ ហើយគាត់ក្បង់ទឹកលប់មុខឲ្យខ្ញុំ រួចគាត់និយាយថា "កូនស្រីម្តាយ កូនបែកចេញ ពីម្តាយហើយ តែកូនអត់អីទេ ខំថែខ្លួនផង" ។ ពេលនឹកខ្ញុំ ម្តាយខ្ញុំតែងតែមកឈរនៅមាត់ព្រៃកនេះឈរសម្លឹង និងចង់ចូលទៅរកខ្ញុំនៅខាងក្នុង ប៉ុន្តែគាត់មិនអាចចូលទៅរកខ្ញុំ បានឡើយ" ។

ស្នាដៃសម្លាប់រង្គាលរបស់តាម៉ុកក្នុងមន្ទីរសន្តិសុខភូមិភាគនិរតីនៅភ្នំជ្រែអូញ៉េ បានរួមចំណែកធ្វើឲ្យតាម៉ុកក្លាយជាជនឈានមុខក្នុងចលនាបុព្វហេតុបម្រើមាគ៌ាបដិវត្តន៍ក្រហមឆ្អិនឆ្អៅរបស់ខ្មែរក្រហម ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ។ ផ្ទុយមកវិញស្នាដៃរបស់ជនឈានមុខមហាលោភផ្តោះ មហាអស្ចារ្យរូបនេះបានធ្វើឲ្យស្ត្រី និងកុមារជាប្រពន្ធ និងកូនរបស់បុរសដែលខ្មែរក្រហមចោទថា ក្បត់រាប់ម៉ឺននាក់បាត់បង់ជីវិត ហើយស្ត្រី និងកុមារមួយចំនួនដែលសល់ពីស្លាប់ បាននឹងកំពុងទទួលរងនូវការលំបាកវេទនា និងឈឺចាប់គ្មានថ្ងៃបំភ្លេច ។

**ទីតាំងសម្លាប់ព្រៃស្តេច** លេខកូដភូមិសាស្ត្រៈ ០៥០៣០៤

ទីតាំងសម្លាប់ព្រៃស្តេច ស្ថិតនៅក្នុងភូមិព្រៃស្តេច ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ហើយស្ថិតនៅចំនុចខ្សែស្រប N 11º 20' 31:11" និងរយៈទទឹង E 104º 43' 20:25" តាមការកំណត់នៃម៉ាស៊ីនកត់ត្រាភូមិសាស្ត្រតាមផ្កាយរណប ។ អ្នកទោសជាច្រើនដែលយកមកពីមន្ទីរសន្តិសុខជ្រែអូរញ៉េ ត្រូវបានយកមកសម្លាប់ទាំងឡានៗនៅព្រៃស្តេចនេះ ។ លោកតា សាយ អេង អាយុ៧២ឆ្នាំ បានប្រាប់ថា គាត់ជាអ្នកគាស់រណ្តៅសាកសពនៅភូមិព្រៃស្តេចកាលពីឆ្នាំ១៩៨០ ។ លោកតាបន្តថា ការគាស់នេះគឺដើម្បីរកមាស និងគ្រឿងអលង្ការផ្សេងៗដែលនៅជាប់នឹងខ្លួនសាកសព ។ សាកសពខ្លះមិនទាន់រលួយទេ ហើយមានចំនួនច្រើនណាស់ ។ គាត់ថារណ្តៅដែលគាស់បានមានចំនួនប្រហែល២០រណ្តៅ ហើយមានឆ្អឹងលលាដ៍ក្បាលចំនួនប្រហែលជា៦០០លលាដ៍ក្បាល ។ អ្នកមីងអោម ផល្លី និយាយថា ពេលគាស់រណ្តៅខ្មោច អ្នកស្រុកស្ទើរតែនៅមិនបាន ព្រោះស្អុយពោក ប៉ុន្តែអ្នកជីកនៅតែបន្តជីក ដើម្បីរកមាស ។ អ្នកមីងបន្តថា សាកសពដែលបានស្លាប់នៅទីនេះ(ព្រៃស្តេច) ស្ទើរតែទាំងអស់ សុទ្ធតែយកមកពីគុកជ្រែអូរញ៉េ ។